ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy

លេខ: ០២៥.១៧.ក្រកសរ.រចជា

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកតំបន់សម្បទានរ៉ែសម្រាប់ការដាក់ពាក្យសុំអាជ្ញាបណ្ណស្វែងរុករករ៉ែលោហៈ

ក្រសួងរ៉ែ និងថាមពល សូមជម្រាបជូនដល់បណ្តាក្រុមហ៊ុនរ៉ែក្នុង និងក្រៅប្រទេស ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា តំបន់សម្បទានរ៉ែចំនួន ០១ ទីតាំង ស្ថិតនៅតំបន់ឃុំតាសាញ និង ឃុំកំពង់ល្ពៅ ស្រុកសំឡូត ខេត្តបាត់ដំបង មានផ្ទៃដីសម្រាប់ធ្វើការស្វែងរុករករ៉ែលោហៈចំនួន ១៤៩ (មួយរយសែសិបប្រាំបួន) គីឡូម៉ែត្រក្រឡា ដូចមាន «ផែនទីទីតាំង និងកូអ័រដោណេ» បង្ហាញ និងជូនភ្ជាប់មកជាមួយនេះ ត្រូវបានប្រកាសបើកសម្រាប់បណ្តាក្រុមហ៊ុនរ៉ែក្នុង និងក្រៅប្រទេស ដាក់ពាក្យសុំអាជ្ញាបណ្ណស្វែងរុករករ៉ែលោហៈ ចាប់ពីថ្ងៃនៃសេចក្តីជូនដំណឹងនេះ រហូតដល់ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៧ ។

ក្រុមហ៊ុនរ៉ែដែលមានចំណាប់អារម្មណ៍អាចស្នើសុំ «ពាក្យសុំអាជ្ញាបណ្ណស្វែងរុករករ៉ែលោហៈ» នៅនាយកដ្ឋានគ្រប់គ្រងការស្វែងរុករករ៉ែ អគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងរ៉ែ និងថាមពល អគារលេខ ៧៩-៨៩ វិថីប៉ាស្ទ័រ (ផ្លូវលេខ ៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ នៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទំនាក់ទំនង ០១២-៥០១ ១៩៥/ ០១២-៤៨០ ៩៧៧)។

ចំពោះក្រុមហ៊ុនរ៉ែ ដែលបាន និងកំពុងកាន់អាជ្ញាបណ្ណធនធានរ៉ែលើសពីមួយ ពុំមានសិទ្ធដាក់ពាក្យសុំអាជ្ញាបណ្ណស្វែងរុករករ៉ែលោហៈនេះទេ។

ពាក្យសុំអាជ្ញាបណ្ណស្វែងរុករករ៉ែលោហៈដែលបានបំពេញរួច ត្រូវភ្ជាប់មកជាមួយនូវឯកសារ និងរបាយការណ៍តម្រូវពាក់ព័ន្ធ ហើយដាក់ក្នុងស្រោមសំបុត្របិទជិត រួចប្រគល់ជូន «ការិយាល័យច្រកចេញចូលតែមួយ» របស់ក្រសួងរ៉ែ និងថាមពល យ៉ាងយូរបំផុតត្រឹមថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៧ វេលាម៉ោង ១៧:០០ នាទី ។

ប្រធានក្រុមហ៊ុនត្រូវមកដាក់សំណុំឯកសារសុំអាជ្ញាបណ្ណស្វែងរុករករ៉ែលោហៈដោយផ្ទាល់ ឬប្រគល់សិទ្ធិជូនអ្នកតំណាងរបស់ខ្លួនដាក់ជំនួសក៏បាន ប៉ុន្តែត្រូវមាន «លិខិតប្រគល់សិទ្ធិ» ពីប្រធានក្រុមហ៊ុន ។

ក្រសួងរ៉ែ និងថាមពលនឹងពិនិត្យ និងសម្រេចផ្តល់អាជ្ញាបណ្ណស្វែងរុករករ៉ែលោហៈជូនក្រុមហ៊ុនដែលបានជ្រើសរើសរួច បន្ទាប់ពីក្រុមហ៊ុននោះបានអនុវត្តតាមនីតិវិធីចប់សព្វគ្រប់នៃអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១៦ និងបានដោះស្រាយបណ្តឹងតវ៉ាបានរួចរាល់ជាស្ថាពរ ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០១៧
**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**ស៊ុយ_សែម**

**ចម្លងជូនៈ**
- គ្រប់មន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត «ដើម្បីជូនជ្រាប និងផ្សព្វផ្សាយ»
- ឯកសារ-កាលប្បវត្តិ

# ផែនទីទីតាំងកូអរដោណេតំបន់សម្បទានពិសេសម្រាប់ផ្តល់អាជ្ញាបណ្ណស្វែងរុករករ៉ែលោហៈ

# នៅតំបន់ឃុំតាសាញ និងឃុំកំពង់ល្ពៅ ស្រុកសំឡូត ខេត្តបាត់ដំបង




Coordinate System : WGS_1984_UTM_Zone_48N




**Legend**

តំបន់សម្បទានដែលត្រូវស្វែងរុករករ៉ែ

ផ្ទៃដីសរុបទាំងអស់ ១៤៩.០០ គីឡូម៉ែត្រការ៉េ

កូអរដោណេតំបន់សិក្សាស្រាវជ្រាវរ៉ែលោហៈ

| | | | | | |
|---|---|---|---|---|---|
| A | 269581 | 1400324 | E | 273581 | 1404324 |
| B | 271081 | 1400324 | F | 279581 | 1404324 |
| C | 271081 | 1402324 | G | 279581 | 1388324 |
| D | 273581 | 1402324 | H | 269581 | 1388324 |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ១២៦៩.រ៥./ឥកសរ

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០១៧

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**
**ជម្រាបមក**
**លោកប្រធានមន្ទីររ៉ែ និងថាមពលរាជធានី-ខេត្តទាំងអស់**

**កម្មវត្ថុ៖** សំណើបិទផ្សព្វផ្សាយ«សេចក្តីជូនដំណឹងស្តីពីការបើកតំបន់សម្បទានរ៉ែសម្រាប់ការដាក់ពាក្យសុំអាជ្ញាបណ្ណស្វែងរុករករ៉ែលោហៈ» របស់ក្រសួងរ៉ែ និងថាមពល។

**យោង៖**
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណស្វែងរុករក និងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ។
- សារាចរលេខ ៣៦០ រប.គ្រកសរ.សរច ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៦ ស្តីពីនីតិវិធី និងដំណើរការនៃការទទួលពាក្យស្នើសុំ ការពិនិត្យ និងការវាយតម្លៃ និងការឆ្លើយតបលើពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករក (ធនធានរ៉ែ) ។

អត្ថន័យដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានមន្ទីររាជធានី-ខេត្តទាំងអស់ឲ្យបានជ្រាបថា តំបន់សម្បទានរ៉ែចំនួន០១ទីតាំង ស្ថិតនៅតំបន់ឃុំតាសាញ និងឃុំកំពង់ល្ពៅ ស្រុកសំឡូត ខេត្តបាត់ដំបង មានផ្ទៃដីសម្រាប់ធ្វើការស្វែងរុករករ៉ែលោហៈចំនួន ១៤៩ (មួយរយសែសិបប្រាំបួន) គីឡូម៉ែត្រក្រឡា ដូចមាន «ផែនទីទីតាំង និងកូអ័រដោណេ» បង្ហាញ និងជូនភ្ជាប់មកជាមួយនេះ ត្រូវបានប្រកាសបើកសម្រាប់បណ្តាក្រុមហ៊ុនរ៉ែក្នុង និងក្រៅប្រទេស ដាក់ពាក្យសុំអាជ្ញាបណ្ណស្វែងរុករករ៉ែលោហៈ ចាប់ពីថ្ងៃនៃសេចក្តីជូនដំណឹងនេះ រហូតដល់ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៧ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោកប្រធានមន្ទីររាជធានី-ខេត្តទាំងអស់ ជ្រាប ហើយធ្វើការបិទផ្សព្វផ្សាយ «សេចក្តីជូនដំណឹង» នេះ ដែលមានខ្លឹមសារ និងផែនទីបង្ហាញទីតាំង ជូនភ្ជាប់មកជាមួយនេះ ឲ្យបានទទួលលទ្ធផលល្អប្រសើរ ។

សូម លោកប្រធានមន្ទីររាជធានី-ខេត្តទាំងអស់ ទទួលនូវការរាប់អានពីខ្ញុំ ។

**ចម្លងជូន៖**
- គ្រប់រដ្ឋបាលសាលារាជធានី-ខេត្ត
  «ដើម្បីជូនជ្រាប»
- ឯកសារ- កាលប្បវត្តិ

**ស៊ុយ_សែម**